THE WORLD BANK

Working for a World Free of Poverty

# សេចក្តីប្រកាសព័ត៌មាន

**សេចក្តីប្រកាសព័ត៌មានៈ** 2011/361/EAP

**Contacts:**
*In Washington:*
Carl P. Hanlon, 1 202 473-8087
chanlon@worldbank.org
*In Phnom Penh:*
Bou Saroeun,(855 23) 217 301
sbou@worldbank.org

## ក្រុមប្រឹក្សានាយកប្រតិបត្តិរបស់ធនាគារពិភពលោក ពិចារណាលើរបាយការណ៍របស់ក្រុមអធិការកិច្ចស្តីពី គម្រោងគ្រប់គ្រងដីធ្លី និងរដ្ឋបាលនៅកម្ពុជា

**ទីក្រុងវ៉ាស៊ីងតោន ថ្ងៃទី០៨ ខែ មីនា ឆ្នាំ២០១១**- ក្រុមប្រឹក្សានាយកប្រតិបត្តិរបស់ធនាគារពិភពលោក បានជួបប្រជុំនៅថ្ងៃនេ ដើម្បីពិភាក្សាអំពីការស៊ើបអង្កេតរបស់ក្រុមអធិការកិច្ចទៅលើ គម្រោងគ្រប់គ្រងដីធ្លី និងរដ្ឋបាល **(LMAP)** និងសំណើនានារបស់ថ្នាក់គ្រប់គ្រងធនាគារពិភពលោក ដែលឆ្លើយតបទៅនឹងលទ្ធផលរកឃើញរបស់ក្រុមអធិការកិច្ច។

ក្រុមប្រឹក្សានេះបានពិចារណាអំពីរបាយការណ៍របស់ក្រុមអធិការកិច្ច និងបានព្រមព្រៀងលើផែនការសកម្ម-ភាពរបស់ថ្នាក់គ្រប់គ្រងចំពោះការដោះស្រាយបញ្ហានានាដែលក្រុមអធិការកិច្ចបានលើកឡើង។

របាការណ៍ស៊ើបអង្កេតរបស់ក្រុមអធិការកិច្ចកត់សម្គាល់ឃើញថា ជាក់ស្តែង គម្រោងនេះ"ផ្តល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋប្រហែលមួយលានគ្រួសារ" និងទទួលស្គាល់នូវ"សមិទ្ធិផលដ៏សំខាន់របស់គម្រោងគ្រប់គ្រងដីធ្លី និងរដ្ឋបាល។ ភាគច្រើន គម្រោងនេះបានផ្តល់ឱ្យប្រជាពលរដ្ឋកម្ពុជាក្រីក្រចំនួន១.២៤លាននាក់នូវប័ណ្ណកម្មសិទ្ធិដី ហើយគម្រោងនេះមានគោលដៅផ្តល់នូវលទ្ធភាពក្នុងការទទួលបានដីធ្លីប្រកបដោយភាពត្រឹមត្រូវ និងតម្លាភាពនៅក្នុងប្រទេសដែលសិទ្ធិកាន់កាប់ដីធ្លីត្រូវបានបំផ្លិចផ្លាញដោយសារតែជម្លោះជាច្រើនទសវត្សរ៍។ របាយការណ៍នេះយល់ស្របទៅនឹងទស្សនៈដែលថា ការទទួលបានសិទ្ធិកាន់កាប់ដីធ្លីគឺមានសារៈសំខាន់ណាស់ក្នុងការកាត់បន្ថយភាពក្រីក្រប្រកបដោយចីរភាពនៅក្នុងប្រទេសកម្ពុជា។

ក្រុមអធិការកិច្ចនេះក៏បានរកឃើញថា មានបញ្ហាជាច្រើន ដែលភាគច្រើនក្នុងចំណោមបញ្ហាទាំងនោះ ថ្នាក់គ្រប់គ្រងបានកំណត់នៅក្នុងរបាយការណ៍លើកដំបូងនៅក្នុងឆ្នាំ២០០៩។ ប្រជាពលរដ្ឋនៅតំបន់បឹងកក់ត្រូវបានបដិសេធមិនឱ្យទទួលបានដំណើរការវិនិច្ឆ័យដ៏ត្រឹមត្រូវអំពីការទាមទារដីធ្លីរបស់ពួកគេនោះទេ ហើយថែមទាំងត្រូវបានបណ្តេញ

ចេញ ដោយបំពានលើគោលនយោបាយរបស់ធនាគារពិភពលោក ដែលបានព្រមព្រៀងជាមួយរដ្ឋាភិបាលក្នុងការដោះស្រាយការតាំងលំនៅជាថ្មី។ ថ្នាក់គ្រប់គ្រងនេះមិនបានពិនិត្យតាមដានឱ្យបានត្រឹមត្រូវទៅលើការពង្រឹងការយល់ដឹងរបស់សាធារណជន និងការចូលរួមពីសហគមន៍នោះទេ ហើយថែមទាំងពន្យាពេលអនុវត្តយន្តការដោះស្រាយជម្លោះ និងជំនួយក្នុងការធ្វើឱ្យការគ្រប់គ្រងដីរដ្ឋប្រសើរឡើង។ ក្រុមនេះក៏បានយល់ឃើញថា ថ្នាក់គ្រប់គ្រងនេះធ្វើការយឺតយ៉ាវពេកមិនអាចឆ្លើយតបទៅនឹងការបណ្តេញចេញនោះបាន។

លោក រ៉ូបើត ហ្សេលិក **(Robert Zoellick)** ប្រធានធនាគារពិភពលោក បានមានប្រសាសន៍ថា *"យើងព្រួយបារម្ភជាខ្លាំង និងមិនសប្បាយចិត្ត ចំពោះប្រជាពលរដ្ឋដែលកំពុងតែត្រូវគេបង្ខំឱ្យចាកចេញពីផ្ទះសម្បែងរបស់ខ្លួន។ យើងបានខិតខំធ្វើការ ដើម្បីព្យាយាមជួយពួកគាត់ជាមួយនឹងផែនការសកម្មភាពដែលផ្តល់ហិរញ្ញប្បទាន និងការប្រឹក្សាយោបល់ផ្នែកបច្ចេកទេសដល់រដ្ឋាភិបាល ដើម្បីរកដំណោះស្រាយជាសារវន្ត។ យើងបើកទូលាយរកមធ្យោបាយផ្សេងទៀត ដើម្បីជួយប្រជាពលរដ្ឋទាំងនេះ។ យើងបានអំពាវនាវម្តងហើយម្តងទៀតសុំឱ្យរដ្ឋាភិបាលបញ្ឈប់ការបណ្តេញចេញទាំងនេះ។ យើងកំពុងសុំចម្លើយជាវិជ្ជមានពីរដ្ឋាភិបាល"*។

ការស៊ើបអង្កេតរបស់ក្រុមអធិការកិច្ចត្រូវបានធ្វើឡើង ជាការឆ្លើយតបទៅនឹងសំណើសុំអធិការកិច្ចកាលពីថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០០៩ ដោយអង្គការមិនមែនរដ្ឋាភិបាល តាងនាមឱ្យប្រជាពលរដ្ឋនៅក្នុងតំបន់បឹងកក់ ស្ថិតនៅចំកណ្តាលរាជធានីភ្នំពេញ ដែលត្រូវបានបណ្តេញចេញទាំងបង្ខំដោយសាលារាជធានីភ្នំពេញ និងក្រុមហ៊ុនអភិវឌ្ឍន៍ឯកជនមួយ ដើម្បីធ្វើផ្លូវសម្រាប់ការអភិវឌ្ឍន៍ថ្មី។ របាយការណ៍របស់ក្រុមអធិការកិច្ចនេះបានផ្តោតទៅលើថា តើធនាគារពិភពលោកបានអនុវត្តតាមគោលនយោបាយរបស់ខ្លួនដែរឬយ៉ាងណា ក្នុងនោះរួមមាន គោលនយោបាយក្នុងអំឡុងពេលធ្វើគម្រោង អនុវត្ត និងត្រួតពិនិត្យគម្រោងគ្រប់គ្រងដីធ្លី និងរដ្ឋបាល ។

ប្រជាពលរដ្ឋនៅតំបន់បឹងកក់បានចោទថា ការបណ្តេញចេញទាំងនេះត្រូវបានអនុវត្តដោយបំពានលើកិច្ចព្រមព្រៀងនៃក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងលំនៅជាថ្មីដែលត្រូវបានបង្កើតឡើងក្រោមគម្រោងគ្រប់គ្រងដីធ្លី និងរដ្ឋបាល និងអាចអនុវត្តទៅបានចំពោះការបណ្តេញប្រជាពលរដ្ឋចេញពីដីរដ្ឋនៅក្នុងតំបន់គម្រោងផ្តល់ប័ណ្ណកម្មសិទ្ធិដី។

ឥណទានរបស់សមាគមអភិវឌ្ឍន៍អន្តរជាតិ (IDA) សម្រាប់គម្រោងរៀបចំ និងគ្រប់គ្រងដីធ្លី (LMAP) ទទួលបានការព្រមព្រៀងពីក្រុមប្រឹក្សានាយកប្រតិបត្តិ កាលពីថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០២ ដែលមានទឹកប្រាក់ស្មើនឹង ២៤.៣លានដុល្លារសហរដ្ឋអាមេរិក។ គម្រោងនេះត្រូវបានគ្រោងធ្វើឡើង ដើម្បីទ្រទ្រង់ដំណាក់កាលទី១នៃផែនការរយៈពេលវែងរបស់រដ្ឋាភិបាលកម្ពុជា ក្នុងការបង្កើតប្រព័ន្ធរដ្ឋបាលដីធ្លីបែបទំនើប តាមរយៈការធ្វើឱ្យសន្តិសុខប័ណ្ណ

កម្មសិទ្ធិដីធ្លីប្រសើរឡើង និងលើកស្ទួយដល់ការអភិវឌ្ឍន៍ទីផ្សារដីធ្លីប្រកបដោយប្រសិទ្ធភាព។ ប្រទេសកាណាដា ហ្វាំងឡង់ និងអាល្លឺម៉ង់ក៏បានផ្តល់សហហិរញ្ញប្បទានដល់គម្រោងនេះផងដែរ។ ប្រព័ន្ធរដ្ឋបាលដីធ្លីនៅកម្ពុជាភាគច្រើនត្រូវបានបំផ្លាញក្នុងអំឡុងសម័យខ្មែរក្រហម។

រដ្ឋាភិបាលបានលុបចោលហិរញ្ញប្បទានសម្រាប់គម្រោងនេះ កាលពីថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៩ បន្ទាប់ពីធនាគារពិភពលោកបានស្នើសុំផ្អាកជាបួមនៃគម្រោងនេះ ដោយរង់ចាំការពិភាក្សាអំពីការអនុវត្តន៍គោលនយោបាយការពាររបស់ខ្លួនចំពោះការដោះស្រាយបញ្ហានៃការតាំងលំនៅជាថ្មី។

លោក **Roberto Lenton** ប្រធានក្រុមអធិការកិច្ច បានមានប្រសាសន៍ថា *"ការទាមទាររបស់សហគមន៍បឹងកក់មានលក្ខណៈធ្ងន់ធ្ងរ។ បញ្ហាដែលបានលើកឡើងទាំងនេះទាក់ទងនឹងសំណួរសំខាន់ៗអំពីសិទ្ធិកាន់កាប់ដីធ្លី និងសុវត្ថិភាពកម្មសិទ្ធិដី។ ក្នុងការវាយតម្លៃលើការអនុវត្តន៍របស់គណៈគ្រប់គ្រងធនាគារពិភពលោក ក្រុមអធិការកិច្ចនេះបានរកឃើញថា ការបណ្តេញចេញទាំងនេះបានប្រព្រឹត្តទៅដោយបំពានលើគោលនយោបាយរបស់ធនាគារពិភពលោកស្តីពីការតាំងលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត និងបានបង្កឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងរដល់គ្រួសារ និងសហគមន៍ដែលរងគ្រោះទាំងនេះ។ ក្រុមអធិការកិច្ចនេះកត់សម្គាល់អំពីសារៈសំខាន់ជាសារវន្តនៃសកម្មភាពនានា ក្នុងការដោះស្រាយផលប៉ះពាល់ដែលប្រជាពលរដ្ឋទាំងនេះរងគ្រោះនៅក្នុងតំបន់គម្រោង និងការអនុវត្តន៍ការងាររបស់គណៈគ្រប់គ្រងធនាគារពិភពលោកចំពោះគោលនយោបាយរបស់ធនាគារ រួមមាន ការតាំងលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត។"*

ធនាគារពិភពលោកបានស្វះស្វែងបន្តទំនាក់ទំនងថ្នាក់ខ្ពស់ជាមួយរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍នានា ដោយធ្វើដំណើរឆ្ពោះទៅមុខ ដើម្បីគាំទ្រដល់សហគមន៍រងគ្រោះនានា ដោយឆ្លើយតបទៅនឹងការអភិវឌ្ឍន៍ និងតម្រូវការជីវភាពរស់នៅរបស់ពួកគេ។ ថ្នាក់គ្រប់គ្រងនេះបានស្នើសុំរាយការណ៍ត្រឡប់ទៅក្រុមប្រឹក្សានាយកប្រតិបត្តិវិញ អំពីការអនុវត្តន៍ផែនការសកម្មភាពក្នុងរយៈពេល៦០ថ្ងៃ។

លោក **Annette Dixon** នាយិកាប្រចាំប្រទេសនៅកម្ពុជាបានមានប្រសាសន៍ថា *"យើងអំពាវនាវឱ្យរដ្ឋាភិបាលបញ្ឈប់ការបណ្តេញចេញ និងរកមធ្យោបាយជួយប្រជាពលរដ្ឋ។ ក្នុងរយៈពេលប៉ុន្មានទសវត្សរ៍កន្លងមកនេះ ប្រទេសកម្ពុជាបានឆ្លងកាត់ការរីកលូតលាស់ផ្នែកសេដ្ឋកិច្ចកម្រិតខ្ពស់ ដោយនាំឱ្យសម្ពាធទៅលើដីធ្លីមានការកើនឡើង។ ការបង្កើតរដ្ឋបាលដីធ្លីដ៏ត្រឹមត្រូវ និងយុត្តិធម៌មិនចាំបាច់ត្រូវអនុវត្តក្នុងដំណាក់កាលនៃការអភិវឌ្ឍសេដ្ឋកិច្ចដ៏ឆាប់រហ័ស។ យើងធានាថា មេរៀនដែលបានសិក្សាពីគម្រោងនេះនឹងត្រូវបានអនុវត្តឱ្យកាន់ទូលំទូលាយថែមទៀត។"*

###

**ក្រុមអធិការកិច្ចនេះ** ត្រូវបានបង្កើតឡើងតាមរយៈសេចក្តីសម្រេចដូចគ្នារបស់ក្រុមប្រឹក្សានាយកប្រតិបត្តិនៃធនាគារអន្តរជាតិដើម្បីការស្តារឡើងវិញ និងអភិវឌ្ឍន៍ (IBRD) និងសមាគមអភិវឌ្ឍន៍អន្តរជាតិ (IDA) នៅក្នុងឆ្នាំ ១៩៩៣។ ក្នុងការឆ្លើយតបទៅនឹងពាក្យបណ្តឹងពីបណ្តាសហគមន៍ដែលរងគ្រោះដោយគម្រោងនេះ ក្រុមអធិការកិច្ចគឺជាយន្តការឯករាជ្យ គណនេយ្យភាព និងឧបាស្រ័យ "ដែលមានការចូលរួមពីថ្នាក់ក្រោម" ដែលស៊ើបអង្កេតគម្រោងផ្តល់ហិរញ្ញវត្ថុដោយ IBRD/IDA ដើម្បីកំណត់ថា តើធនាគារនេះបានអនុវត្តតាមគោលនយោបាយ និងនីតិវិធីប្រតិបត្តិរបស់ខ្លួនដែរឬយ៉ាងណា (រួមមាន ការការពារផ្នែកសង្គម និងបរិស្ថាន) និងដើម្បីដោះស្រាយបញ្ហាពាក់ព័ន្ធនៃការប្រឈមគ្រោះថ្នាក់។

http://web.worldbank.org/WBSITE/EXTERNAL/EXTINSPECTIONPANEL/0,,menuPK:64132057~pagePK:64130364~piPK:64132056~theSitePK:380794,00.html

សម្រាប់ព័ត៌មានបន្ថែមអំពីធនាគារពិភពលោកនៅកម្ពុជា សូមចូលទៅកាន់គេហទំព័រ: www.worldbank.org/kh